ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
ក្រុមការងារទី៤

**សូមគោរពជូន**

**លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ**

**និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)**

**តាមរយៈ**÷ លោកជំទាវ ឧត្តមសេនីយ៍ឯក ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ

**កម្មវត្ថុ**÷ របាយការណ៍ស្តីពីការរៀបចំកិច្ចប្រជុំត្រីភាគី កម្ពុជា ឡាវ វៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្លងកាត់ព្រំដែន កម្រិតបច្ចេកទេស ។

**យោង** ÷ លិខិតលេខ ១៣៤/២៤ ស.ណ ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០២៤ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអភិសន្តិបណ្ឌិត** ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៤។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ មេត្តាជ្រាបថា៖ នៅថ្ងៃចន្ទ-អង្គារ ៨-៩រោច ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៣-២៤ ខែធ្នូ ឆ្នាំ២០២៤ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) បានរៀបចំកិច្ចប្រជុំត្រីភាគី កម្ពុជា ឡាវ វៀតណាម ស្តីពី កិច្ចសហប្រតិបត្តិការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្លងកាត់ព្រំដែន កម្រិតបច្ចេកទេស នៅសណ្ឋាគារ Empress Angkor Resort & Spa ខេត្តសៀមរាប។

**គោលបំណង នៃកិច្ចប្រជុំ៖**

១.ផ្លាស់ប្តូរព័ត៌មាន អំពីនិន្នាការនៃបទល្មើស និន្នាការនៃប្រជាពលរដ្ឋដែលធ្វើចំណាកស្រុក ស្ថានភាពនៃភាពងាយរងគ្រោះរបស់ជនទេសន្តរប្រវេសន៍ឆ្លងកាត់ព្រំដែន នៃប្រទេសទាំងបី និងបទពិសោធន៍ក្នុងការដោះស្រាយបញ្ហាប្រឈម

២.សិក្សាអំពី យន្តការគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍ឆ្លងកាត់ព្រំដែន របស់រដ្ឋាភិបាលនៃប្រទេសទាំងបី ភាពប្រឈមលើការអនុវត្តយន្តការដែលមានស្រាប់ និងកិច្ចសហការរវាងប្រទេសទាំងបី ក្នុងការទប់ស្កាត់ការកេងប្រវ័ញ្ច និងជួញដូរមនុស្សឆ្លងដែន

៣.ស្វែងរកដំណោះស្រាយរួម ដើម្បីបង្កើនប្រសិទ្ធិភាពក្នុងការគ្រប់គ្រងលំហូរឆ្លងកាត់ព្រំដែន និងពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ សំដៅដល់ការធ្វើទេសន្តរប្រវេសន៍ ប្រកបដោយសុវត្ថិភាព រៀបរយនិងស្របច្បាប់

៤.គំនិតផ្តួចផ្តើម លើកទិសដៅក្នុងការបង្កើតយន្តការត្រីភាគី និងនីតិវិធីជាក់លាក់ដែលឯកភាពគ្នាសម្រាប់ការគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍ រៀបចំកិច្ចប្រជុំទៀងទាត់ ដើម្បីចែករំលែកព័ត៌មាន និងកិច្ចសហការបន្ត ។

**I.សមាសភាពគណៈប្រតិភូទាំង ៣ ប្រទេស**

២. ប្រតិភូសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដឹកនាំដោយ ឯកឧត្តម ឧត្តមសេនីយ៍ KHONGSAVAT BOUNLIENG អគ្គនាយករង នៃអគ្គនាយកដ្ឋាននគរបាលសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ (Deputy Chief of Lao Police, General Department of Police) និងជាតំណាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឡាវ (National Committee on Anti Trafficking in Person) និងមានការចូលរួមពីអង្គភាពពាក់ព័ន្ធចំនួន ០៦រូប និងតំណាងស្ថានទូតឡាវប្រចាំព្រះរាជាណាចក្រកម្ពុជា។

៣. ប្រតិភូសាធារណរដ្ឋសង្គមនិយមវៀតណាម ដឹកនាំដោយ Senior Col. Vu Van Dau អគ្គនាយករង នៃនាយកដ្ឋាននគរបាលព្រហ្មទណ្ឌវៀតណាម (Deputy Director General Criminal Police Department) ដោយមានការចូលរួមពីអង្គភាពពាក់ព័ន្ធ និងមន្ត្រីក្រសួងការបរទេសវៀតណាម សរុបចំនួន ០៦រូប។

តាមរយៈស្មារតីនៃកិច្ចប្រជុំដែលមានរយៈពេល០២ថ្ងៃ ប្រតិភូនៃប្រទេសទាំងបី បានឯកភាព និងទទួលថា អំពើជួញដូរមនុស្សជាបទល្មើសដែលមានអង្គការចាត់តាំង និងទម្រង់ជាបទល្មើសឧក្រិដ្ឋកម្មឆ្លងដែន ដែលចាំបាច់ត្រូវមានកិច្ចសហប្រតិបត្តិការជាអន្តរជាតិ។ អង្គប្រជុំបានពិគ្រោះពិភាក្សា និងផ្លាស់ប្តូរចែករំលែកបទពិសោធន៍គ្នាទៅវិញទៅមកក្នុងស្មារតីនៃកិច្ចសហការ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

១) បានស្វែងយល់ពីភាពងាយរងគ្រោះចម្បងនៃជនទេសន្តរប្រវេសន៍ឆ្លងដែននៃប្រទេសទាំងបី ព្រមទាំងបានធ្វើបច្ចុប្បន្នភាពពីស្ថានភាពបច្ចុប្បន្ននៃការគ្រប់គ្រងទេសន្តរប្រវេសន៍ឆ្លងដែន និងរបត់ថ្មីនៃអំពើជួញដូរមនុស្សដូចជាការជួញដូរមនុស្សដោយប្រើប្រាស់បច្ចេកវិទ្យាទាក់ទងទំនើប។

Understood main vulnerabilities of migrants across the borders of the three countries including updates on current situation of cross-border migration management and new trends of human trafficking such as trafficking using modern communication technology.

២) បានចែករំលែកបទពិសោធន៍ជោគជ័យ និងបញ្ហាប្រឈមនៃយន្តការឆ្លើយតបរបស់រាជរដ្ឋាភិបាលនៃប្រទេសទាំងបី។

Shared experiences including successes and challenges related to the response mechanisms of the governments of the three countries.

៣) បានទទួលស្គាល់នូវតម្រូវការនៃការពង្រឹងបន្ថែម នូវកិច្ចសហប្រតិបត្តិការក្នុងចំណោមអាជ្ញាធរពាក់ព័ន្ធ នៃប្រទេសទាំងបី ដើម្បីបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព នៃការគ្រប់គ្រងព្រំដែន ការពារជនងាយរងគ្រោះពីស្ថានភាពហានិភ័យដែលបង្កដោយបណ្តាញជនល្មើស។

Acknowledged the needs to strengthen more collaboration among relevant authorities of the three countries to improve effectiveness and efficiency of border management to protect vulnerable people from risky situation committed by perpetrator networks.

៤) បានកត់សម្គាល់ឃើញថា សកម្មភាពបង្ការទប់ស្កាត់ គួរតែត្រូវបានផ្តល់អាទិភាព ដោយសារការបង្ការទប់ស្កាត់មានភាពចាំបាច់ក្នុងការការពារមនុស្សពីគ្រប់ទម្រង់នៃការជួញដូរមនុស្ស និងការកេងប្រវ័ញ្ច ក្នុងនោះធ្វើឡើងតាមរយៈយុទ្ធនាការលើកកម្ពស់ការយល់ដឹងនៅកម្រិតសហគមន៍ ពីទេសន្តរប្រវេសន៍ខុសច្បាប់ និងអំពើជួញដូរមនុស្ស។

Recognized that prevention activity should be prioritized as it is crucial to protect people from all forms of trafficking and exploitation via awareness-raising campaign at community level on unsafe migration and trafficking in persons.

៥) បានព្រមព្រៀងធ្វើការពិភាក្សាបន្ថែមលើការបង្កើតនូវយន្តការចែករំលែកព័ត៌មាន ដើម្បីឆ្លើយតបទៅនឹងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ច និងដើម្បីបង្កើនជំនួយសម្រាប់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស។

Agreed to have further discussions on the establishment of information-sharing mechanisms to respond to all forms of trafficking and exploitation and to improve assistance for victims of human trafficking.

៦) បានព្រមព្រៀងឱ្យមានកិច្ចប្រជុំតាមដានត្រីភាគី ដើម្បីពិភាក្សាលើការត្រៀមរៀបចំសកម្មភាពបន្តបន្ទាប់ដែលបានព្រមព្រៀងគ្នាដោយប្រតិភូនៃប្រទេសទាំងបី។
Agreed to have a follow-up tripartite meeting to discuss on the preparation of upcoming activities that were agreed by the three delegations.

លទ្ធផលខាងលើនេះ ប្រតិភូនៃប្រទេសទាំងបី (កម្ពុជា ឡាវ វៀតណាម) បានឯកភាពគ្នាជាគោលការណ៍ ប៉ុន្តែសម្រាប់ប្រតិភូវៀតណាម ស្នើសុំមិនទាន់ចុះហត្ថលេខាលើកំណត់ហេតុនៃកិច្ចប្រជុំភ្លាមៗនោះទេ ដោយរង់ចាំគោរពសុំការអនុញ្ញាត និងរាយការណ៍ជូនថ្នាក់ដឹកនាំ នៃប្រទេសវៀតណាមជាមុនសិន ដោយសន្យានឹងបញ្ជូនលិខិតឆ្លើយតបជាផ្លូវការវិញ មុនថ្ងៃទី ០៥ ខែមករា ឆ្នាំ២០២៥។ ផ្អែកតាមសំណើរបស់ប្រតិភូវៀតណាម កំណត់ហេតុនៃកិច្ចប្រជុំមិនបានចុះហត្ថលេខាទេ ដោយរង់ចាំលិខិតឆ្លើយតបជាផ្លូវការរបស់ប្រតិភូវៀតណាម។ (គោរពជូនភ្ជាប់ជាមួយនូវ៖ កំណត់ហេតុកិច្ចប្រជុំចំនួន០១ច្បាប់, កម្មវិធីចំនួន ០១ច្បាប់ និងសមាសភាពអ្នកចូលរួមចំនួន ០១ច្បាប់)

អាស្រ័យហេតុដូចបានគោរពជម្រាបជូនខាងលើ សូម **លោកជំទាវ រដ្ឋលេខាធិការ និងជាអនុប្រធានអចិន្ត្រៃយ៍** គ.ជ.ប.ជ មេត្តាពិនិត្យ សម្រេច និងគោរពសុំមតិដឹកនាំដ៏ខ្ពង់ខ្ពស់។

សូម **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

ថ្ងៃចន្ទ ១កើត ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៤
**ប្រធានក្រុមការងារទី៤**

ឧត្តមសេនីយ៍ទោ កែវ សុវណ្ណារ៉ា

បានពិនិត្យ និងសូមគោរពជូន
លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ មេត្តាជ្រាប និងគោរពសុំមតិដឹកនាំដ៏ខ្ពង់ខ្ពស់។
ថ្ងៃពុធ ៣កើត ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ១ ខែមករា ឆ្នាំ២០២៥
**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯក វេជ្ជ.ប៉ុណ្ណ សំខាន់

បានឃើញ
01/01/25

ជួ_ប៊ុនអេង